# ការបង្រៀន និងរៀនប្រកបដោយគុណភាព

(QUALITY TEACHING AND LEARNING)

*ដោយ* : **បណ្ឌិត សូ សុធីរ**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ការបង្រៀន និងការរៀនប្រកបដោយគុណភាព ជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំដោយប្រសិទ្ធភាព និងដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំការអភិវឌ្ឍការសិក្សាសង្គម និងចិត្តរំភើបរបស់អ្នកសិក្សា។ នៅពេលដែលស្តង់ដាពិភពលោកក្នុងការអប់រំមានការវិវត្ត មានការសង្កត់ធ្ងន់កាន់តែខ្លាំងឡើង មិនត្រឹមតែអ្វីដែលត្រូវបានបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែ របៀបដែលវាត្រូវបានបង្រៀន និងរបៀប ដែលសិស្សរៀនបានល្អ។ ការបង្រៀនប្រកបដោយគុណភាពពាក់ព័ន្ធនឹងការប្រើប្រាស់ល្បិចបង្រៀនប្រកបដោយប្រសិទ្ធភាព ការយល់ដឹងយ៉ាងស៊ីជម្រៅអំពីប្រធានបទ និងសមត្ថភាពក្នុងការចូលរួម និងគាំទ្រសិស្សមកពីមជ្ឈដ្ឋានចម្រុះ។ ដូចគ្នាដែរ ការរៀនសូត្រប្រកបដោយគុណភាពកើតឡើងនៅពេលដែលសិស្សចូលរួមយ៉ាងសកម្មគិតពិចារណា និងអនុវត្តចំណេះដឹងតាមមធ្យោបាយប្រកបដោយអត្ថន័យ។ ឯកសារនេះ ស្វែងយល់ពីធាតុសំខាន់ៗនៃការបង្រៀន និងការរៀនប្រកបដោយគុណភាព បញ្ហាប្រឈមដែលអ្នកអប់រំប្រឈមមុខ និងយុទ្ធសាស្ត្រសម្រាប់ជំរុញឧត្តមភាពក្នុងបរិយាកាសអប់រំ។*

*ជាង៥០ ឆ្នាំកន្លងទៅ មានការអភិវឌ្ឍជាច្រើន ដែលក្នុងនោះ បញ្ញត្តិនៃការបង្រៀនប្រកប ដោយប្រសិទ្ធភាព ត្រូវបានកំណត់ន័យនិងបញ្ញត្តិ ដែលអ្នកស្រាវជ្រាវសិក្សាបានច្រើនជាងមុន អំពីការបង្រៀន និងរៀន។ និយមន័យមួយ ដែលសង្ខេបនូវសញ្ញាណ ដែលទទួលបានទូទៅច្រើនបំផុតនៃប្រសិទ្ធភាពរបស់គ្រូគឺ៖*

*គ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព គឺជាគ្រូម្នាក់ ដែលធ្វើឱ្យសិស្សទទួលបានលទ្ធផលសិក្សាជាអតិបរមា និងដែលធ្វើ*

សកម្មភាពប្រកបដោយភាពច្បាស់លាស់ តាមគោលការណ៍ ដែលមានលំដាប់លំដោយ មានការជាប់ពាក់ព័ន្ធ និងទាក់ទងដល់បរិបទនៃការបង្រៀន។

គោលវិធីថ្មីមួយ ដើម្បីអភិវឌ្ឍដូចជា "គោលការណ៍ដ៏ជាក់លាក់មួយចំនួន" បានបង្កើតនូវរបៀបថ្មីមួយនៃការពិនិត្យមើលការបង្រៀនដ៏មានប្រសិទ្ធភាព គឺគោលវិធីដែលត្រូវបានគេហៅថា "គរុកោសល្យផលិតផល" ត្រូវបានអភិវឌ្ឍផ្នែកមួយនៃគម្រោងកំណែទម្រង់សាលារៀន។ វាបានចាប់ផ្តើមជាសម្មតិកម្មនៃការស្រាវជ្រាវតាមបែបសង្កេត និងពិសោធទៅជាប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូដោយផ្តោតការយកចិត្តទុកដាក់ តាមទម្រង់នៃការប្រតិបត្តិក្នុងថ្នាក់រៀន ដែលរួមបានចំណែកដល់ការសិក្សាប្រកបដោយប្រសិទ្ធភាពសម្រាប់សិស្សទាំងអស់គ្នា ដោយមិនបានចាត់ទុកដល់ប្រវត្តិការសិក្សា វប្បធម៌ ឬសង្គមទេ។ ឯកសាររំឭកឡើងវិញដ៏ទូលំទូលាយបែបនេះទាក់ទាញយ៉ាងច្រើនដល់ "គំរូគរុកោសល្យដ៏ត្រឹមត្រូវ" របស់លោក ញូមែន និងសហសេវិករបស់គាត់ នៅឆ្នាំ១៩៩៦ ដែលត្រូវបានស្ថាបនាពីលក្ខណៈវិនិច្ឆ័យ៩ យ៉ាងសម្រាប់ការបង្រៀនដ៏ត្រឹមត្រូវតាមច្បាប់ ដែលបានអភិវឌ្ឍ។ តាមគោលវិធីបង្រៀនបែបនេះ លក្ខណៈពិសេសដោយឡែកនៃស្នាដៃបញ្ញវន្ត ប្រកបដោយភាពត្រឹមត្រូវ តាមច្បាប់គឺ "ការស្ថាបនាពុទ្ធិ" តាម "សង្កេតដែលប្រកបដោយវិន័យ" ដើម្បីបង្ហាញនូវការបញ្ចេញយោបល់ ផលិតផល ឬការបញ្ចោញស្នាដៃដែលមាន "តម្លៃហួសពីសាលារៀន"។ គំរូរបស់លោកញូមែន មានភាពដូចគ្នាជាមួយនឹងគោលវិធីការបង្រៀនដើម្បីយល់ដឹង "(teaching for understanding) របស់លោកប្រូភី។ គំរូគរុកោសល្យដែលទទួលបានផ្ទៃផ្កា គឺស្របគ្នាខ្លាំងនឹងគោលការណ៍ការអប់រំផ្អែកលើលទ្ធផល ដែលបានស្នើដោយលោក ស្ប៉ែតឌី។

គំរូនៃការបង្រៀនតាមចំណុចទាំង៤ និងការប្រតិបត្តិតាមការវាយតម្លៃ ដែលនិយាយយោងទៅដល់គរុកោសល្យផលិតផល (Product- tie Pedagogy) ត្រូវបានគេរៀបចំពីប្រភពដើម ដើម្បីរៀបរាប់មជ្ឈដ្ឋានសិក្សា នៅក្នុងថ្នាក់រៀន ល្បិចបង្រៀន និងកិច្ចការ ដែលសិស្សចូលរួម។ ក្រោយមកវាត្រូវបានគេអនុវត្តដើម្បីវិភាគទម្រង់ការនៃការវាយតម្លៃ និងដើម្បីឆ្លើយតបនឹងសិស្ស ចំពោះកិច្ចការវាយតម្លៃ។ ចំណុចទាំង៤នៃគំរូ ដែលត្រូវបានគេដឹងនាពេលថ្មីៗនេះថា ជាគុណភាពបញ្ញា (Intellectual quality) ភាពពាក់ព័ន្ធ (Relevance or connectedness) មជ្ឈដ្ឋានសិក្សាដែលបាន

ទ្រទ្រង់ដោយសង្គម (Social supportive learning environment) និងការស្គាល់ឡើងវិញពីភាពខុសគ្នា (Recognition of difference)។ គំរូនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីស្រាវជ្រាវការប្រតិបត្តិគរុកោសល្យនៃគ្រូបង្រៀន។

## ១-គុណភាពបញ្ញា

មុខងារដ៏សំខាន់បំផុតមួយ គឺដើម្បីជួយសិស្ស ដកយកចំណុចសំខាន់ពីពុទ្ធិ និងការយល់ដឹងពីព័ត៌មានដ៏ច្រើន ដែលគេអាចជួបប្រទះ នៅពេលដែលការសិក្សាទៅលើប្រធានបទថ្មីណាមួយ។ ការជួយសិស្សឱ្យផ្លាស់ប្តូរព័ត៌មាន (អត្ថបទ រូបភាព សំឡេង...) ទៅជាពុទ្ធិ (ភាពដែលបានចេះដឹងតាមបទពិសោធ) ហើយបន្ទាប់មកទៅជាការយល់ដឹង (ការចូលរួមដ៏មានន័យ) ទាមទារនូវការពិចារណាដ៏ប្រុងប្រយ័ត្ននៃធម្មជាតិ ពីអ្វីដែលបានរៀន និងការចេះដឹងពីរបៀប ដែលសិស្សរៀន។ មានការស្រាវជ្រាវមួយ ដែលគួរពិចារណាជាកស្តុតាង ដែលចង្អុលបង្ហាញថាការសិក្សារបស់សិស្ស បានកែលម្អ នៅពេលដែលចូលរួមក្នុងការគិតកម្រិតខ្ពស់ នៅពេលដែលការសិក្សា ផ្តោតទៅលើពុទ្ធិដ៏ជ្រាលជ្រៅនៃប្រធានបទ នៅពេលដែលគរុកោសល្យផ្តោតទៅលើការផ្តល់ការយល់ដឹងដ៏ជ្រាលជ្រៅ ហើយនៅពេលដែលសិស្ស ចូលរួមក្នុងទំនាក់ទំនងដ៏សំខាន់ អំពីរបៀបដែលគេកំពុងសិក្សា។ ទម្រង់នៃការសិក្សាបែបនេះទំនងជាកើតឡើង នៅពេលដែលចំណេះដឹងត្រូវបានបង្កើតបញ្ហា នៅពេលសិស្សដឹងពីរបៀបផ្សេងៗ ដែលសិស្សត្រូវប្រើ ដើម្បីបង្កើតរូបរាង និងប្រែរូបទៅជាពុទ្ធិខ្ពស់ (metalanguage)។ ជាតុនីមួយៗ ត្រូវបានពន្យល់ដូចតទៅៈ

### ក-ចំណេះដឹងដ៏ជ្រាលជ្រៅ

មានជាតុបីៈ

១-ទីមួយវាជាការប្រមូលផ្តុំនៃគោលការណ៍ និងគំនិតសំខាន់ ដែលបង្កើតមូលដ្ឋាននៃគោលការណ៍ ឬប្រធានបទសិក្សា។

២-ទីពីគឺបណ្តាញនៃទំនាក់ទំនង ក្នុងចំណោមគំនិតសំខាន់ទាំងនេះ។

៣-ហើយទីបី គឺវាជាទំនាក់ទំនងរវាងគំនិតសំខាន់ទាំងនោះ និងចំណេះដឹងផ្សេងទៀត ដែលគាំទ្រដល់គោលការណ៍។

គេត្រូវតែផ្តល់ឱកាសឱ្យសិស្សសិក្សាដើម្បីស្រាវជ្រាវទៅលើពុទ្ធិដ៏ជ្រាលជ្រៅ ក្នុងវិស័យសិក្សារបស់គេ ហើយរឿងនេះ នឹងមិនកើតឡើងទេ ប្រសិនបើវាត្រូវបានបង្ហាញដ៏ងាយស្រួលជាមួយបរិមាណដ៏ច្រើននៃព័ត៌មានមិនសំខាន់ ឬគំនិតដែលបែងចែកជា

ផ្នែកៗ ទាំងគំនិតសំខាន់ និងទំនាក់ទំនងរបស់វា គួរត្រូវបានបង្រៀនយ៉ាងច្បាស់លាស់។

**ខ-ការយល់ដឹងដ៏ជ្រាលជ្រៅ**

កើតឡើងនៅពេលដែលសិស្សអភិវឌ្ឍការយល់ដឹង តាមរចនាសម្ព័ន្ធដ៏ល្អរួមបញ្ចូលគ្នា និងពេញលេញពីរបៀប ដែលក្នុងនោះគំនិតសំខាន់ ដែលគេកំពុងសិក្សា មានការពាក់ព័ន្ធពីគ្នា ទៅវិញទៅមក និងទៅចំណេះដឹងមួយទៀត។ សិស្សដែលមានការយល់ដឹងជ្រាលជ្រៅ គឺអាចមានលទ្ធភាព ប្រើចំណេះដឹងជ្រាលជ្រៅរបស់គេដើម្បីដោះស្រាយបញ្ហាស្មុគស្មាញ ទៅដល់ការសន្និដ្ឋានសមហេតុផល និងរុករកធម្មជាតិនៃបញ្ហាពុទ្ធិ។ គេអាចប្រើមុខងារពុទ្ធិតាមបែបច្នៃប្រឌិត និងវាយតម្លៃ ដែលគរុវិទូ បានដាក់នៅកម្រិតកំពូលនៃចំណាត់ថ្នាក់ពុទ្ធិ។ លក្ខណៈដ៏សំខាន់នៃការយល់ដឹងដ៏ជ្រាលជ្រៅ គឺថាវាជាមានភាពរឹងមាំ វានៅស្ថិតស្ថេរជាជាងការបាត់បង់ក្នុងរយៈពេលខ្លី។ សិស្សដែលមានការយល់ដឹងជ្រាលជ្រៅ យល់ដឹងពីព្រំដែននៃពុទ្ធិរបស់គេ និងផែនកំណត់ ដែលអាចអនុវត្តបាន។

**គ-ការគិតកម្រិតខ្ពស់**

ប្រភេទនៃលំនាំពុទ្ធិ ដែលបានកើតឡើង នៅកម្រិតខ្ពស់នៃឋានានុក្រមការគិត ដែលទទួលបាន ដូចជា កម្រិតចំណាត់ថ្នាក់របស់លោកប្លូម នៅឆ្នាំ1956។ កម្រិតចំណាត់ថ្នាក់ត្រូវកែលម្អ នាពេលថ្មីៗនេះ ដើម្បីពិចារណាទ្រឹស្តីនៃការសិក្សាទំនើបថែមទៀត ហើយឥឡូវនេះ ផ្តល់ភាពបន្តគ្នានៃលំនាំពុទ្ធិ ដែលចាប់ផ្តើមពីការចងចាំ និងការអភិវឌ្ឍតាមការយល់ដឹង ការអនុវត្ត ការវិភាគ និងការវាយតម្លៃ ទៅដល់ការច្នៃប្រឌិត។ លំនាំពុទ្ធិពាក់កណ្តាលផ្នែកខាងលើនៃកម្រិតចំណាត់ថ្នាក់នេះ ត្រូវបាននិយាយយោងទៅដល់ការគិតកម្រិតខ្ពស់ ពីព្រោះវាទាមទារឱ្យសិស្សចូលរួម ក្នុងការគិតស្មុគស្មាញទាក់ទងនឹងបរិបទ ដើម្បីប្រើយ៉ាងប៉ិនប្រសប់ ទាំងព័ត៌មាន និងទាំងគំនិតអរូបី តាមរបៀប ដែលធ្វើឱ្យប្រែរូបរាងដល់អត្ថន័យរបស់គេ។ វាទាមទារឱ្យសិស្ស ធ្វើការវិនិច្ឆ័យអំពីបញ្ហាមិនប្រាកដ និងដើម្បីអនុវត្តលក្ខណៈវិនិច្ឆ័យ។ នៅពេលដែលសិស្ស ចូលរួមក្នុងការគិតកម្រិតខ្ពស់ គេនឹងទាមទារជាយថាហេតុ ដើម្បីពន្យល់ (Explain) ធ្វើទូទៅកម្ម (Generalize) ធ្វើសំយោគ (Synthesis) បង្កើតសម្មតិកម្ម (Hypothesis) បកស្រាយ (Interpret) និងកសាងចំណេះដឹងថ្មី (Construct new knowledge)។ លទ្ធផលដ៏ជាក់លាក់នៃលំនាំទាំងនេះ ជាញឹកញាប់ មិនអាចទស្សន៍ទាយទុកមុនបានទេ។ ដើម្បីជំរុញការគិតកម្រិត

ខ្ពស់ គ្រូត្រូវតែបង្កើតរចនាសម្ព័ន្ធកិច្ចការសិក្សារបស់សិស្សដែលនឹងទាមទារឱ្យសិស្សធ្វើឱ្យបាន ច្រើនជាងការអនុវត្តតាមទម្រង់ការដដែលៗយ៉ាងសាមញ្ញ និងប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវពុទ្ធិ ដែលមិនទាន់ជាក់លាក់ ការគិតកម្រិតខ្ពស់ ទំនងជាមិនបានកើតឡើងទេ ប្រសិនបើគ្រូមិនបានចូលរួមក្នុងសកម្មភាពទាំងឡាយ ដែលជំរុញយ៉ាងខ្លាំងដល់ការគិតកម្រិតខ្ពស់ ហើយប្រសិនបើគាត់មិនបានបង្រៀនសិស្សពីរបៀបចូលរួមក្នុងកិច្ចការនៃការគិតដ៏ស្មុគស្មាញទាំងនេះ។

របៀបដែលយើង ទទួលបានចំណេះដឹង និងលំនាំដែលឈានទៅដល់ការយល់ដឹង គឺផ្តល់មូលដ្ឋានសម្រាប់ប្រតិបត្តិ។ គ្រូអាចបង្កើតពុទ្ធិជាអង្គមិនប្រែប្រួលនៃព័ត៌មានដែលត្រូវច្នៃ និងទទួល ឬជាការយល់ដឹងមួយលំដាប់ ដែលត្រូវស្ថាបនាឡើង តាមអន្តរកម្មរបស់សិស្សជាមួយនឹងបរិស្ថាន។ ប្រសិនបើយើងពិចារណាលើទស្សនៈចុងក្រោយ ដូច្នោះ ចំណេះដឹងអាចត្រូវបានគេមើលឃើញថាជារឿងពិបាកយល់ គឺបើកទូលាយ ដល់បញ្ហា និងការពិភាក្សា។ សិស្សអាចបញ្ចេញឱ្យឃើញទម្រង់ទំនាស់ជាសក្តានុពល និងផ្ទុយគ្នា ជាច្រើននៃពុទ្ធិ និងទស្សនៈវិស័យទៅលើពុទ្ធិ។ សិស្សអាចលើកទឹកចិត្ត ដើម្បីស្រាវជ្រាវឥទ្ធិពលវប្បធម៌សង្គម និងនយោបាយទៅលើពុទ្ធិ និងការអនុវត្តនៃឥទ្ធិពលទាំងនេះ។ ភាពខុសគ្នា ដែលបង្កើតបានពុទ្ធិ អាចផ្លាស់ប្តូរដោយផ្ទាល់ និងពេញលេញ ដែលអាចនាំទៅដល់ការប្រតិបត្តិគរុកោសល្យ (Pedagogical Practices) ដែលមិនបានលើកទឹកចិត្តដល់ការពិភាក្សា (Discourage Discussion) សហប្រតិបត្តិការ (Collaboration) ការចរចា (Negotiation) និងការអភិវឌ្ឍន៍ន័យរួម (The Development of Shared Meanings)។

គ្រូមិនអាចបង្ហាញអត្ថន័យបានទេ ប្រសិនបើមិនបានប្រើភាសា។ ព្រោះហេតុដូច្នេះ ហើយវាជារឿងសំខាន់សម្រាប់គ្រូដើម្បីជួយសិស្សឱ្យយល់៖

១-របៀបសិក្សាអត្ថបទបែបសរសេរ និងនិយាយ។

២-មូលហេតុដែលវាក្យសព្ទបច្ចេកទេសជាកលាក់ អាចត្រូវបានគេប្រើ។

៣-របៀបរចនាសម្ព័ន្ធល្បះ (សម្ព័ន្ធ និងវេយ្យាករណ៍) មានឥទ្ធិពលដល់អត្ថន័យ។

៤-របៀប ដែលអត្ថន័យត្រូវបានគេបង្ហាញឱ្យឃើញ(និយណ្ណសាស្ត្រ)។

៥-មូលហេតុដែលប្រភេទផ្សេងៗនៃអត្ថបទ ត្រូវបានគេប្រើប្រាស់។

*ការប៉ុនប៉ងដោយចេតនាទាំងនេះ ដើម្បីកំណត់ន័យ និងរបៀបដែលភាសាបង្កើតបាន ជារូបរាង និងប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវរបៀប ដែលមនុស្សគិត និងយល់នូវប្រធានបទ ត្រូវបានគេនិយាយយោងទៅដល់ថាជាភាសា ដែលប្រើដើម្បីរៀបរាប់ និងពិភាក្សាភាសា។*

**ឃ-ទំនាក់ទំនងដ៏សំខាន់**

*កើតមានឡើងនៅកន្លែងណា ដែលការផ្លាស់ប្តូរដោយមានការគាំទ្រ ឬការសន្ទនារវាងគ្រូ និងសិស្ស (ហើយនៅក្នុងចំណោមសិស្ស) អំពីបញ្ញត្តិដ៏សំខាន់ និងគំនិតដែលគេកំពុងតែជួបប្រទះ។ ការពិភាក្សាទាំងនេះ គួរតែលាតត្រដាងការគិតប្រកបដោយគុណភាព (ការអនុវត្តគំនិត ការធ្វើសម្មតិកម្ម ការលើកឡើងនូវសំណួរទាំងឡាយ) មិនគ្រាន់តែការថាឡើងវិញនូវព្រឹត្តិការណ៍ទាំង ឡាយ ការបញ្ចេញមតិដោយគំនិតមិនសំខាន់ ឬការរៀបរាប់ពីបទពិសោធទាំងឡាយ។ ប្រភេទនៃការពិភាក្សាទាំងនេះ ជួយសិស្សឱ្យស្ថាបនាគំនិតរបស់គេ និងអភិវឌ្ឍការយល់ដឹងរួមនៃពុទ្ធិដ៏ជ្រាលជ្រៅនៃប្រធានបទ។*

*ចំណុចគុណភាពបញ្ញានៃគំរូការបង្រៀនប្រកបដោយគុណភាព គឺផ្អែកលើគុណភាព ដែលថា លទ្ធផលសិស្ស ប្រកបដោយគុណភាពខ្ពស់ ទទួលបានលទ្ធផលប្រសិនបើការសិក្សា ផ្តោតទៅលើការសិក្សាប្រកបដោយបញ្ញា ដែលជាការបញ្ចេញសមត្ថភាពផ្តោតលើបញ្ញត្តិ និងគំនិតដ៏សំខាន់ និងទាមទារឱ្យមានកិច្ចព្រមព្រៀងតាមបែបពុទ្ធិដ៏សំខាន់ជាមួយចំណេះដឹងដ៏ជ្រាលជ្រៅ។ នៅក្នុងទម្រង់នៃការបង្រៀននេះ គេមិនរំពឹងថា សិស្សចងចាំព័ត៌មានងាយស្រួល ហើយបន្ទាប់មកអាចរំឭក និងថាឡើងវិញបាន។ ជាងនេះទៅទៀត គេរំពឹងថានឹងបកស្រាយ និងធ្វើសំយោគព័ត៌មានពន្យល់ពីមូលហេតុ ដែលចម្លើយមួយចំនួនប្រសើរជាងចម្លើយផ្សេងៗទៀត ហើយដោះស្រាយបញ្ហា ដែលមិនធ្លាប់ស្គាល់ ដែលអាចមានច្រើនជាងដំណោះស្រាយគួរឱ្យធ្វើបាន។*

## ២-បរិស្ថានការសិក្សាប្រកបដោយគុណភាព

*នេះជាបរិស្ថានដែលសិស្សដឹងថា គេត្រូវបានគេគោរពនិងមានសុវត្ថិភាពពីអន្តរកម្មសង្គមអវិជ្ជមាន ដែលជាកន្លែងគេគួរទុកចិត្តដើម្បីនិយាយពីរបៀប និងពេលណាដែលគេត្រូវសិក្សា និងជាកន្លែងដែលគេរំពឹងថានឹងប្រឹងប្រែងរៀនសូត្រ ដើម្បីទទួលបានលទ្ធផលខ្ពស់ដែលត្រូវបានបង្កើតដោយភាពច្បាស់លាស់។ គំនិតទាំងនេះ ត្រូវបានគេតាងតាម*

ជាតុដូចតទៅ នៃគំរូបង្រៀនប្រកប ដោយគុណភាពៈ

**ក-លក្ខណៈវិនិច្ឆ័យគុណភាព ដោយជាក់លាក់**

គ្រូត្រូវជានាថាអ្វីជាលទ្ធផលដ៏សំខាន់ ដែលគេទាមទារឱ្យសម្រេចបាន និងរបៀប ដែលគុណភាពនៃសមិទ្ធផលរបស់គេនៃ លទ្ធផលទាំងនេះ នឹងត្រូវបានវិនិច្ឆ័យ។ គ្រូចាំបាច់បង្កើតការនិយាយយោងដល់ភាពទៀងទាត់ចំពោះ លក្ខណៈវិនិច្ឆ័យទាំងនេះ នៅពេលដែលគេបង្រៀន និងពេល ដែលគេវាយតម្លៃការសិក្សារបស់សិស្ស។

**ខ-ក្តីសង្ឃឹមដ៏ខ្ពស់**

មិនមែនសិស្សទាំងអស់ នឹងទទួលបានការយល់ដឹងដូចគ្នាទេ ប៉ុន្តែ គ្រូគួរតែរំពឹងថា សិស្សទាំងអស់គ្នា សម្រេចបានលទ្ធផលដ៏សំខាន់ដល់កម្រិតខ្ពស់មួយ។ នេះជាគោលការណ៍មូលដ្ឋានមួយនៃលទ្ធផល ដែលផ្អែកលើការអប់រំ។ សាលារៀនទាំងឡាយ ដែលបង្កើតក្តីសង្ឃឹមដ៏ខ្ពស់សម្រាប់សិស្សទាំងអស់គ្នា និងផ្តល់ការគាំទ្រចាំបាច់សម្រាប់សិស្ស ដើម្បីសម្រេចបានក្តីសង្ឃឹមទាំងនេះ មានអត្រានៃភាពជោគជ័យក្នុងការសិក្សាខ្ពស់ជាងសាលាទាំងឡាយ ដែលមានក្តីសង្ឃឹមដដែលៗដល់សិស្សមួយចំនួនថា នឹងទទួលបានជោគជ័យ។ គ្រូដែលមានក្តីសង្ឃឹមខ្ពស់ព្យាយាមស្តាបនាកម្លាំងសិស្ស សមត្ថភាព ចំណូលចិត្ត និងស្តាបនាទំនាក់ទំនង ដែលបង្ហាញឱ្យឃើញនូវចំណូលចិត្តទៅលើសិស្ស និងការសិក្សារបស់គេ។ គេក៏ព្យាយាមផងដែរ ដល់ការសម្របសម្រួលបែបបទការសិក្សារបស់សិស្សឱ្យបានទូលំទូលាយនិងពហុបញ្ញា ដើម្បីបង្ហាញឱ្យឃើញថា គេឱ្យតម្លៃដល់កម្លាំងនិងបញ្ញា តែមួយនៃបុគ្គលតែមួយ។

**គ-ការចូលរួមក្នុងការសិក្សា**

សកម្មភាពបង្រៀន ត្រូវតែរៀបចំឱ្យបានត្រឹមត្រូវ ដើម្បីឱ្យសិស្សមានឱកាសសមរម្យ ដើម្បីចូលរួមការសិក្សាប្រកបដោយអត្ថន័យ។ ការចូលរួមក្នុងការសិក្សា នឹងមានភាពច្បាស់លាស់ នៅពេលណាដែលសិស្សប្រឹងប្រែងធ្វើកិច្ចការ ដោយផ្តោតអារម្មណ៍ទៅលើបញ្ហាសំខាន់ និងការខិតខំសិក្សាប្រកបដោយញាណ។ សិស្សចាំបាច់ ចូលរួមដោយហ្មត់ចត់ក្នុងការសិក្សា ដើម្បីឱ្យសម្រេចបានការយល់ដឹងច្បាស់លាស់។ ការចូលរួមក្នុងការសិក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធដល់កត្តីភាព និងចលករសិក្សា និងដល់កម្មជាតិនៃអន្តរកម្មជាមួយប្រព័ន្ធសង្គមថ្នាក់រៀន។

**ឃ-ការគាំទ្រចូលរួម ដើម្បីសមិទ្ធផលសិស្ស**

គំនិតដ៏សំខាន់នៅទីនេះ គឺថាគ្រូ និងសាលារៀន គួរតែរំពឹងថា សិស្សសម្រេចបាន

ផលសិក្សា និងគួរតែបង្កើតបរិស្ថានសិក្សាប្រកបដោយការច្នៃប្រឌិត ដែលនឹងជំរុញដល់ភាពជោគជ័យ។ វាចាប់ផ្តើមឡើងជាមួយគ្រូដែលកំពុងអភិវឌ្ឍការគិតឃើញត្រឹមត្រូវពីសហគមន៍ក្នុងថ្នាក់រៀន និងវាយតម្លៃពីប្រវត្តិដើមទស្សនៈ និងជំនឿពីអ្នកផ្សេងទៀត។ នៅពេលដែលទំនាស់កើតឡើងគេត្រូវតែដោះស្រាយប្រកបដោយការស្ថាបនា ដើម្បីឱ្យគេជំរុញការយល់ដឹងជាជាងការពង្រឹងបុរេវិនិច្ឆ័យ។ ការប្រឹងប្រែងលើការសិក្សាទាំងអស់ ត្រូវតែមានការលើកទឹកចិត្ត និងការគាំទ្រ។

**ខ-ស្វ័យបទបញ្ជាដល់សិស្ស**

គ្រូគួរតែលើកទឹកចិត្ត និងទាមទារឱ្យសិស្សកែតម្រូវ ដោយទៀងទាត់នូវអាកប្បកិរិយាផ្ទាល់ខ្លួនរបស់គេ ដើម្បីឱ្យមានតម្រូវការអប្បបរមា សម្រាប់គ្រូដែលកំពុងមានវិន័យ និងភាពទៀងទាត់។ ល្បិចគ្រូបង្រៀនដូចជា គម្រោងស្រាវជ្រាវ អាចជួយអភិវឌ្ឍស្វ័យភាពទៀងទាត់របស់សិស្ស។

**ច-ការតម្រង់ទិសដល់សិស្ស**

តាមរយៈការចរចា និងការដឹកនាំសិស្ស គួរតែត្រូវបានគេផ្តល់ការគ្រប់ គ្រងឱ្យបានច្រើនដូចដែល អាចអនុវត្តទៅបានលើអ្វី និងរបៀបដែលគេរៀនបែបណា និងត្រូវបានលើកទឹកចិត្តចំពោះ ការទទួលខុសត្រូវសម្រាប់ការសិក្សាផ្ទាល់របស់គេ។ ជាញឹកញាប់រឿងនេះ នឹងពាក់ព័ន្ធដំណើរការប្រើប្រាស់ល្បិចបង្រៀន ដូចជាគម្រោងស្រាវជ្រាវជាបុគ្គលដែលសិស្សបានរៀបចំ។

**៣-ខ្លឹមសារដ៏សំខាន់** (Significance)

រឿងនេះ ផ្អែកទៅលើគំនិតដែលថាការសិក្សាត្រូវបានលើកកម្ពស់នៅពេលណាដែលសិស្សអាចមើលឃើញ ពីរបៀបដែលរឿងរ៉ាវទាំងឡាយដែលគេកំពុងសិក្សា មានការពាក់ព័ន្ធដល់គេ។ រឿងនេះ អាចសម្រេចទៅបានតាម រយៈការផ្សារភ្ជាប់ដល់ពុទ្ធិដើមរបស់គេ ផ្សារភ្ជាប់ការសិក្សារបស់គេ ទៅនឹងពិភពពិតហួសពីថ្នាក់រៀន និងការបញ្ចូលពុទ្ធិតាមព្រំដែនមុខវិជ្ជា។ វាក៏អាចជួយផងដែរនៅពេលណាដែលមានការទទួលស្គាល់ថាសិស្សអាចមាន ប្រភពមកពីភាពផ្សេងៗពីគ្នាខាងផ្នែកប្រវត្តិវប្បធម៌ និងសង្គម និងវាជារឿងដែលអាចធ្វើទៅបាន ដើម្បីស្ថាបនាជាវិជ្ជមាននូវភាពខុសគ្នាទាំងនេះ។ ធាតុទាំង៦នៃចំណុចទាំងនេះត្រូវបានពណ៌នាដូចតទៅៈ

**ក-ប្រវត្តិពុទ្ធិ**

រឿងរ៉ាវទាំងឡាយដែលសិស្សបានយល់ដឹងរួចហើយ គឺជាឥទ្ធិពលដ៏សំខាន់ទៅលើអ្វីដែលគេអាចសិក្សា នៅពេលអនាគត។ ព្រោះហេតុដូច្នេះហើយ ប្រវត្តិពុទ្ធិសិស្ស គួរតែមានការរាប់បញ្ចូលដោយមិនផ្លាស់ប្តូរ និង

ដោយចេតនា ទៅនឹងការសិក្សាថ្មីៗរបស់គេ។ ប្រវត្តិពុទ្ធិនេះ អាចទទួលបានពីបទពិសោធបុគ្គល ការសិក្សាជាផ្លូវការពីពេលមុន ប្រភពវប្បធម៌ និងសហគមន៍។ វានឹងរាប់បញ្ចូលពុទ្ធិពីពិភពលោក វប្បធម៌ និងភាសា។ ប្រវត្តិពុទ្ធិរបស់បុគ្គលម្នាក់ៗ និងបទពិសោធសិក្សាពីពេលមុននឹងជាឥទ្ធិពលដ៏ខ្លាំងទៅលើជំនឿ ចំណូលចិត្តជាងគេ បែបបទសិក្សា និងស្វ័យប្រសិទ្ធភាព។

### ខ-សមាហរ័ណកម្មចំណេះដឹង

នៅពេលដែលការបង្រៀន ត្រូវបានពឹងផ្អែកទៅលើបញ្ហា ដែលតម្រូវឱ្យចំណេះដឹងចេញពីពហុមុខវិជ្ជានោះ គេបាននិយាយថា ចំណេះដឹងមានសមាហរ័ណកម្ម។

ឧទាហរណ៍ៈ ប្រសិនបើគ្រូ អាចភ្ជាប់នូវអ្វីដែលសិស្សកំពុងរៀនខាងគណិតវិទ្យា ទៅនឹងអ្វីដែលគេកំពុងសិក្សាខាងវិទ្យាសាស្ត្រ និងប្រវត្តិសាស្ត្រនោះ រឿងនេះ នឹងជួយសិស្សឱ្យយល់ឃើញថា បញ្ហាពិភពពិតដ៏សំខាន់ មិនត្រូវបានគេកំណត់ព្រំដែន តាមព្រំដែនមុខវិជ្ជាសិក្សា ដែលមានលក្ខណៈជាប្រពៃណីទេ។ ការរួមបញ្ចូលគ្នានៃចំណេះដឹង គឺផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ចំពោះការយល់ដឹងដ៏ជ្រាលជ្រៅ។

### គ-ភាពផ្សារភ្ជាប់គ្នា

វិសាលភាពភាព ដែលការសិក្សាមានការពាក់ព័ន្ធដល់ពិភពពិតរបស់សិស្សនោះ កំណត់វិសាលភាព ដែលវា នឹងផ្តល់តម្លៃ និងមានអត្ថន័យលើសពីការបង្រៀន។ របៀបផ្ទាល់៣ដ៏សំខាន់បំផុត ដើម្បីបង្កើតទំនាក់ទំនងគ្នានោះ គឺៈ

-ធ្វើឱ្យការសិក្សា មានមូលដ្ឋានជុំវិញបទពិសោធផ្ទាល់ខ្លួនរបស់សិស្ស។

-ធ្វើឱ្យការសិក្សា មានមូលដ្ឋានជុំវិញបញ្ហាសាធារណៈ ដែលទាក់ទងនឹងពិភពពិត។

-ផ្តល់ឱ្យសិស្សនូវឱកាសទាំងឡាយ ដើម្បីបែងចែកការងារជាមួយកិច្ចប្រជុំហួសពីថ្នាក់រៀន និងសាលារៀន។

### ឃ-ចំណេះដឹងខាងវប្បធម៌

នៅពេលដែលគ្រូទទួលស្គាល់យ៉ាងច្បាស់លាស់ថា ភាពស្របច្បាប់នៃជំនឿ ភាសា ការ ប្រតិបត្តិវប្បធម៌ និងរបៀបនៃការយល់ដឹងអំពីសិស្សទាំងអស់ និងបង្កើតប្រយោជន៍ពី គំរូដែលពាក់ព័ន្ធខាងវប្បធម៌ រឿងនេះ បង្ហាញថាវប្បធម៌ទាំងអស់ គឺត្រូវបានគេវាយតម្លៃ។ វាក៏បានទទួលស្គាល់ ថា ភាពពិតនៃចំណេះដឹងខាងវប្បធម៌នៃសមាជិករបស់ក្រុមសង្គមដោយផ្អែកលើជាតិពន្ធុ សមធម៌ ភេទ សាសនា...។

### ខ-បរិយាបន្នកម្ម

ការទទួលស្គាល់ និងការវាយតម្លៃនៃភាពខុសគ្នា គឺមិនគ្រប់គ្រាន់ទេ។ វាប្រាកដជាត្រូវបានអភិវឌ្ឍទៅជាការប្រតិបត្តិការបង្រៀន ដែលបានរាប់បញ្ចូលគ្រប់យ៉ាងដែលទទួលស្គាល់យ៉ាងច្បាស់លាស់ និងវាយតម្លៃភាពខុសគ្នា និងលើកទឹកចិត្តដល់ការចូលរួមលើសិស្សខាងប្រវត្តិវប្បធម៌ និងសង្គមទាំងអស់ ដែលជាតំណាងនៅក្នុងថ្នាក់រៀន។

### ច-ការនិទានរឿង

ការប្រើប្រាស់ ឬប្រយោជន៍នៃការនិទានរឿងក្នុងការបង្រៀន ធ្វើឱ្យសិស្សមានអារម្មណ៍ថារឿងផ្ទាល់ខ្លួនបុគ្គលប្រវត្តិវប្បធម៌ និងអក្សរសាស្ត្រ ដែលទាក់ទងនឹងវប្បធម៌មានសារៈសំខាន់។ គ្រូបង្រៀន អាចបង្កើតនិទានរឿងទៅជាខ្លឹមសារបង្រៀន និងទៅជាការបង្ហាញនៅក្នុងថ្នាក់រៀន និងការពិភាក្សា។ ការប្រើប្រាស់នៃករណីសិក្សានិទានរឿង អាចជារឿងមានប្រយោជន៍ដ៏សំខាន់។

## ៤-ការផ្សារភ្ជាប់គុណភាពបង្រៀន ទៅនឹងការអប់រំដែលមានផល

គ្មានអ្វីដែលថ្មីគួរឱ្យភ្ញាក់ផ្អើលក្នុងធាតុនីមួយៗនៃចំណុចទាំង៣ នៃគំរូបង្រៀនប្រកប ដោយគុណភាពទេ។ ពីព្រោះតែវាមានមូលដ្ឋានការស្រាវជ្រាវដ៏រឹងមាំ គំរូនីមួយៗ មានភាពស្រដៀងគ្នា ចំពោះការប៉ុនប៉ងនូវការពណ៌នាការបង្រៀនប្រកបដោយប្រសិទ្ធភាព។

**ឧទាហរណ៍៖** លោកវៃ បានផ្តល់យោបល់ថា ការបង្រៀនដែលមានបំណិនកម្រិតខ្ពស់ អាចមានលក្ខណៈវិនិច្ឆ័យសំខាន់ចំនួន៦គឺ៖

-ការចូលរួមដ៏មានតម្លៃ

-ការគ្រប់គ្រងថ្នាក់រៀនដោយបំណិន

-គរុកោសល្យប្រកបដោយប្រសិទ្ធភាព

-បរិយាកាសថ្នាក់រៀនល្អ

-ការគិតច្បាស់លាស់ អំពីប្រធានបទ

-ការស្រាវជ្រាវដ៏សកម្ម។

ពួកគេបានលាតត្រដាងនូវលក្ខណៈវិនិច្ឆ័យនីមួយៗក្នុងចំណោមទាំងនេះ ទៅជាទិដ្ឋភាពមួយលំដាប់។

**ឧទាហរណ៍៖** "បរិយាកាសថ្នាក់រៀនដ៏ល្អ" ដែលត្រូវបានកំណត់ន័យថាជា "បរិស្ថានសង្គមនៃថ្នាក់រៀន ដែលផ្តល់ការសិក្សា" មានទិដ្ឋភាពផ្សេងគ្នា៥ទៀតគឺ៖

-ការចូលរួម

-ការលើកទឹកចិត្ត

-ទំនាក់ទំនងដ៏ជិតស្និទ្ធ

-ការគោរព

-ភាពរួម ទៅដល់ភាពខុសគ្នាផ្សេងៗ។

វាកំណត់ន័យនូវចំណុចនីមួយៗ ក្នុងវាក្យសព្ទនៃលក្ខណៈពិសេសដ៏ជាក់លាក់នៃការប្រតិបត្តិក្នុងថ្នាក់រៀន។

អ្វីដែលថ្មីនៅក្នុងគំរូបង្រៀនប្រកបដោយគុណភាព គឺជារបៀបដែលទិដ្ឋភាពផ្សេងៗនៃការបង្រៀនប្រកបដោយប្រសិទ្ធភាព ត្រូវបានចាត់ថ្នាក់ក្រុមទៅជាក្របខ័ណ្ឌ ដែលមិនប្រែប្រួលដែលអះអាងដល់ទិដ្ឋភាពសង្គម និងវប្បធម៌នៃការបង្រៀន និងរៀន ព្រមទាំងទិដ្ឋភាពខាងការសិក្សាផ្សេងៗទៀត ដោយមានគរុកោសល្យប្រកបដោយផ្ទៃផ្កា និងគរុកោសល្យប្រកប ដោយតថភាព ដែលមានមែកជាងពីគ្នានោះ គំរូនៃការបង្រៀនប្រកបដោយគុណភាព អះអាងថា តួនាទីដ៏សំខាន់ៗរបស់គ្រូម្នាក់ៗ គឺដើម្បីធ្វើឱ្យកម្រិតអតិបរិមានៃការសិក្សាសម្រាប់សិស្សទាំងអស់គ្នា តាមការអនុវត្តដោយវីរភាព នៃការស្រាវជ្រាវជាក់លាក់ផ្អែកលើគោលការណ៍ទាំឡាយ។ ថ្វីបើគំរូ មួយមានមូលដ្ឋានស្រាវជ្រាវដ៏រឹងមាំនោះ រហូតមកដល់ពេលនេះ វាត្រូវបានគេធ្វើតេស្ត តាមរយៈការស្រាវជ្រាវ ប្រកបដោយភាពម៉ត់ចត់។ វាត្រូវបានធ្វើតេស្ត និងផ្លាស់ប្តូរជាចាំបាច់ទៅតាមពេលវេលា ដូចដែលគ្រូបង្រៀនចូល រួមជាមួយចំណុច និងជាតុនៃគរុកោសល្យក្នុងថ្នាក់។ វាត្រូវបានគេទទឹមរង់ចាំថា គំរូនោះនឹងផ្តល់ក្របខ័ណ្ឌមានប្រយោជន៍សម្រាប់ដឹកនាំស្វ័យឆ្លុះបញ្ចាំងរបស់គ្រូ និងនាំទៅដល់ការកែលំអក្នុងការប្រតិបត្តិការបង្រៀនរបស់គេ។

គំរូទាំងឡាយដូចនេះ ផ្តល់នូវរបៀបដ៏មានប្រយោជន៍ នៃការពិនិត្យនិងការបង្រៀនតាមអំណះអំណាង ខ្លឹមសារជាក់លាក់ ដែលគ្រូគួរតែលើកកម្ពស់ការសិក្សារបស់សិស្ស។

ឧទាហរណ៍ : គ្រូគួរតែចូលរួមជាមួយសិស្សក្នុងការគិតកម្រិតខ្ពស់ និងដើម្បីជួយគេឱ្យសមាហរណ៍កម្មពុទ្ធិតាម ព្រំដែនមុខវិជ្ជាជាប្រពៃណី។ ប៉ុន្តែនៅតែមានបញ្ហាសំខាន់២ គឺ៖

-តើលទ្ធផលបែបណា ដែលយើងគួរតែជួយសិស្សឱ្យសម្រេចបានផល?

-តើខ្លឹសារជាក់លាក់បែបណា ដែលគ្រូអាចធ្វើ ដើម្បីបញ្ចូលជាតុនៃគុណភាពបង្រៀន ទៅជាការប្រតិបត្តិការបង្រៀនរបស់គេ?

ដើម្បីសម្របតាមមូលដ្ឋានទស្សនវិជ្ជានៃគរុកោសល្យដ៏ត្រឹមត្រូវ ដែលយើងគួរតែព្យាយាមជួយសិស្សឱ្យសម្រេចបានលទ្ធផល ដែលលើកកម្ពស់សមត្ថភាពសិស្ស ដើម្បីបង្កើតការនិយាយស្តី ផលិតផលឬការបញ្ចេញ

សមត្ថភាពដែលមានតម្លៃហួសពីសាលារៀន។ រឿងនេះក៏បញ្ជាក់ផងដែរថា ការវាយតម្លៃនៃលទ្ធផលទាំងនេះ គួរតែផ្អែកលើរឿងពិត។ គំនិតទាំងនេះ ស្របតាមក្របខ័ណ្ឌការអប់រំដែលទទួលបានផលដោយផ្តោតលើពេលអនាគត។ គាត់បានបញ្ជាក់ថា តម្រូវការ ដើម្បីមានការផ្តោតអារម្មណ៍ច្បាស់លាស់ ទៅលើលទ្ធផល ដែលគឺជាគុណសម្បត្តិខ្ពស់ ការបកស្រាយដ៏មានកម្រិតខ្ពស់ នៃការសិក្សាប្រកបដោយខ្លឹមសារក្នុងបរិបទមួយ។ ហេតុដូច្នោះហើយ សន្និទានកម្ម ដើម្បីប្រើប្រាស់ការបង្រៀនប្រកបដោយគុណភាព គួរតែជារឿងដែលមានសក្តានុពល ដើម្បីលើកកម្ពស់សិស្សឱ្យសម្រេចបាននូវលទ្ធផលការសិក្សាមួយ ប្រកបដោយខ្លឹមសារ និងតម្លៃ។

ប៉ុន្តែ តើគ្រូអាចធ្វើអ្វីបានដើម្បីឱ្យសិស្សចូលរួមក្នុងប្រភេទនៃការសិក្សាដ៏ជាក់លាក់តាមគំរូបង្រៀនប្រកប ដោយគុណភាព? ជាឧទាហរណ៍ តើគ្រូអាចជួយសិស្សបានយ៉ាងដូចម្តេច ដើម្បីរុករកពុទ្ធិដ៏ជ្រាលជ្រៅនៃប្រធានបទ? បញ្ហានេះ អាចត្រូវបានឆ្លើយតាមពីរកម្រិត គឺទីមួយកម្រិតល្បិច និងទី២ កម្រិតបច្ចេទេស។

-ម្យ៉ាងវិញទៀត ពិតមានល្បិចបង្រៀនជាច្រើន(ដូចជាការសិក្សាតាមបែបសហការ) ដែលអាចច្នៃប្រឌិត ដ៏មានប្រសិទ្ធភាពនូវបរិបទមួយដែលក្នុងនោះ សិស្សអាចចូលរួមក្នុងជាតុទាំងឡាយនៃគំរូការបង្រៀនប្រកបដោយគុណភាព (ដូចជាការគិតកម្រិតខ្ពស់)។

-នៅកម្រិតបច្ចេកទេស មានខ្លឹមសារជាក់លាក់ជាច្រើន ដែលគ្រូអាចធ្វើបាន(ដូចជាសួរនូវប្រភេទសំណួរ ពិតប្រាកដមួយចំនួន) ដើម្បីបង្កើតការប្រើប្រាស់ដ៏មានប្រសិទ្ធភាពនៃល្បិចនីមួយៗ។ តាមន័យនេះ ជាតុនៃគំរូបង្រៀន ប្រកបដោយគុណភាព មានភាពសមរម្យរវាងល្បិច និងបច្ចេកទេស។ គំនិតទាំងនេះ អាចផ្សំបញ្ចូលគ្នានូវអ្វី ដែលគេហៅថា គំរូលទ្ធផលការបង្រៀន និងរៀនប្រកបដោយគុណភាព។ គំរូនេះបញ្ជាក់ពីទំនាក់ទំនងរវាងចំណុចផ្សេងៗនៃការបង្រៀន ដែលនាំឱ្យសិស្ស បកស្រាយលទ្ធផលក្នុងបរិបទ៣៖ ថ្នាក់រៀន សាលារៀន និងពិភពក្រៅពីសាលារៀន)។

គុណភាពនៃការបង្រៀន និងរៀន ផ្តល់សំណើថា សិស្សដែលកំពុងចូលរួមក្នុងជាតុនៃការបង្រៀនប្រកបដោយគុណភាព រួមចំណែកដល់លទ្ធផលការសិក្សារបស់សិស្ស ដែលអាចបកស្រាយតាមបរិបទបី ក្នុងបរិបទចាំបាច់នៃល្បិចបង្រៀន (ឧ.ផ្នែកមួយនៃការពិភាក្សាតាមក្រុម) ក្នុងបរិបទកម្មវិធី

*សិក្សាដ៏ទូលំទូលាយ (ដូចជាក្នុងការប្រឡង) និងក្នុងជីវិតអនាគតកាលរបស់សិស្ស(ដូចជាក្នុងស្ថានភាពធ្វើការងារ)។ លទ្ធផលទាំងនេះនឹងត្រូវកំណត់ន័យ តាមកម្មវិធីសិក្សា និងកម្រិតប្រាថ្នានៃសមិទ្ធផលសិស្សនៃលទ្ធផលដែលអាចរៀបរាប់ តាមការប្រើប្រាស់ឧបករណ៍ដូចជាកម្រិតចំណាត់ថ្នាក់ពុទ្ធិ។ គ្រូត្រូវតែប្រើប្រាស់ល្បិចបង្រៀនសមរម្យ(ដូចជាការងារជាក្រុម ឬការសិក្សាករណីផ្សេងៗ) ដើម្បីផ្តល់បរិបទមួយ ដែលគេអាចប្រើប្រាស់បច្ចេកទេសជាក់លាក់(ដូចជាការផ្តល់ការពន្យល់ដ៏ច្បាស់លាស់ ដើម្បីឱ្យសិស្សចូលរួមក្នុងជាតុនៃការបង្រៀនប្រកបដោយគុណភាព។ គ្រូត្រូវតែលើកទឹកចិត្តសិស្សឱ្យចាប់យកខ្លឹមសារសមរម្យ ឬធនធានសិក្សា ដើម្បីឱ្យគេអាចចូលរួមក្នុងទម្រង់នៃសកម្មភាពការសិក្សាដែលនឹងជួយគេឱ្យសម្រេចបានលទ្ធផល។*

## សន្និដ្ឋាន

*សរុបមក ការបង្រៀន និងការរៀនប្រកបដោយគុណភាព គឺជាចំណុចស្នូលនៃភាពជោគ ជ័យនៃប្រព័ន្ធអប់រំណាមួយ។ វាទាមទារវិធីសាស្ត្ររួមបញ្ចូលអ្នកអប់រំដែលមានជំនាញគរុកោសល្យផ្តោតលើសិស្ស ការអភិវឌ្ឍវិជ្ជាជីវៈដែលកំពុងបន្ត និងបរិយាកាសសិក្សាដែលគាំទ្រ។ នៅពេលដែលអ្នកអប់រំត្រូវបានផ្តល់សិទ្ធិអំណាចជាមួយនឹងឧបករណ៍ និងធនធានត្រឹមត្រូវ ហើយនៅពេលដែលសិស្សត្រូវបានចូលរួមតាមរយៈវិធីសាស្ត្របង្រៀនដែលរួមបញ្ចូល និងមានប្រសិទ្ធភាព ការរៀនសូត្រប្រកបដោយអត្ថន័យកើតឡើង។ តាមរយៈការផ្តល់អាទិភាពលើគុណភាពទាំងការបង្រៀន និងការរៀន ភាគីពាក់ព័ន្ធអាចធានាថា ការអប់រំមិនត្រឹមតែផ្តល់ចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជំរុញការគិតប្រកបដោយភាពច្នៃប្រឌិត និងជំនាញសិក្សាពេញមួយជីវិតរបស់សិស្សផងដែរ។*

# ឯកសារយោង


1. Darling-Hammond, L. (2006). *Powerful Teacher Education: Lessons from Exemplary Programs*. Jossey-Bass.
2. Hattie, J. (2009). *Visible Learning: A Synthesis of Over 800 Meta-Analyses Relating to Achievement*. Routledge.
3. OECD. (2018). *Teaching for the Future: Effective Classroom Practices to Transform Education*. OECD Publishing.
4. Shulman, L. S. (1987). Knowledge and Teaching: Foundations of the New Reform. *Harvard Educational Review*, 57(1), 1–22.
5. UNESCO. (2017). *Education for Sustainable Development Goals: Learning Objectives*. UNESCO Publishing.
6. Bransford, J. D., Brown, A. L., & Cocking, R. R. (Eds.). (2000). *How People Learn: Brain, Mind, Experience, and School*. National Academy Press.
7. Marzano, R. J., Pickering, D. J., & Pollock, J. E. (2001). *Classroom Instruction That Works: Research-Based Strategies for Increasing Student Achievement*. ASCD.
8. Fullan, M. (2011). *The New Meaning of Educational Change* (4th ed.). Teachers College Press.
9. Killen, Roy. (2003). *Effective teaching strategies: Lessons from research and practice.* Social science press.